ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ២៣/២០២៦ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

## ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន អញ្ជើញបំពេញទស្សនកិច្ចការងារ នៅសហរដ្ឋអាមេរិក និងអឺរ៉ុប

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា នឹងអញ្ជើញអម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចនៅសហរដ្ឋអាមេរិក និងអឺរ៉ុប។ ក្នុងអំឡុងពេលនៃបេសកកម្មនៅក្រៅប្រទេសនាសប្តាហ៍ក្រោយនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏នឹងអញ្ជើញបំពេញទស្សនកិច្ចការងារនៅប្រទេសស្វីស និងបារាំង ផងដែរ។

**ឯកឧត្តម ប្រាក់ សុខុន** នឹងអញ្ជើញថ្លែងសុន្ទរកថាក្នុងសម័យប្រជុំលើកទី៦១ នៃក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិនៅទីក្រុងហ្សឺណែវ ដែលនៅទីនោះ**ឯកឧត្តម**គ្រោងនឹងជួបជាមួយប្រធានគណៈប្រតិភូមកពីប្រទេសមួយចំនួនផងដែរ។ នៅចុងបញ្ចប់នៃបេសកកម្មនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** នឹងអញ្ជើញធ្វើដំណើរទៅទីក្រុងប៉ារីស ដើម្បីជួបជាមួយឯកឧត្តម Jean-Noël Barrot រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋបារាំង។ **ឯកឧត្តម ប្រាក់ សុខុន** នឹងពិភាក្សាការងារជាមួយសមភាគីបរទេសនានា ដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគី និងជំរុញកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យដែលមានសក្តានុពលសម្រាប់ផលប្រយោជន៍ទៅវិញទៅមក៕

ថ្ងៃសៅរ៍ ១២រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ ២០២៦

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh